**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ...៣០៧......កប/ប្រ.ក

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០០៧

# ប្រកាស

## ស្តីពីលក្ខខណ្ឌអនាម័យ និងសុវត្ថិភាពការងារ

## ក្នុងរោងចក្រកាត់ដេរសម្លៀកបំពាក់ និងដេរស្បែកជើង

## រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## <u>សម្រេច</u>

**ប្រការ ១.-**

ដោយមិនគិតដល់បទប្បញ្ញត្តិនៃប្រកាសផ្សេងៗដទៃទៀតរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និយោជកនៃសហគ្រាស គ្រឹះស្ថានកាត់ដេរសម្លៀកបំពាក់ និងដេរស្បែកជើងទាំងអស់ ដែលស្ថិតក្នុងដែនអនុវត្តនៃមាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវយកចិត្តទុកដាក់ដល់កម្មករនិយោជិតរបស់ខ្លួនទាំងអស់លើលក្ខខណ្ឌការងារឱ្យមានសុវត្ថិភាព និងមានអនាម័យឧស្សាហកម្មត្រឹមត្រូវ ។

**ប្រការ ២.- រោងជាង ឬការដ្ឋានការងារ**

និយោជកត្រូវរៀបចំស្ថានភាពនៃរោងជាង ឬផ្នែកផលិតកម្មនីមួយៗឱ្យបានសមស្របទៅតាមការងារ ចំនួន

អាសយដ្ឋានអគារលេខ ៣, មហាវិថីសហព័ន្ធរុស្ស៊ី, សង្កាត់ទឹកល្អក់២, ខណ្ឌទួលគោក,ប្រអប់សំបុត្រ P.O Box 1506ទូរស័ព្ទ និង ទូរសារ: (០២៣) ៣៩៣ ៥៣៨

មនុស្ស និងបរិស្ថានជុំវិញ។

- សម្ភារៈការងារ និងសម្ភារៈការពារ ត្រូវមានសភាពសមស្រប មាំទាំ មានប្រសិទ្ធិភាព មិនបង្កឱ្យមានការលំបាក ឬបង្កឱ្យមានគ្រោះថ្នាក់ដល់អ្នកប្រើ ឬអ្នកនៅជិតខាង។

- និយោជកត្រូវខណ្ឌចែករោងជាងដែលមានការងារខុសៗគ្នា ឱ្យនៅដាច់ពីគ្នា ដើម្បីជៀសវាងការ រំខានដោយសារបរិយាកាស សំឡេង ក្លិន ឬធូលីផ្សេងៗ។

- និយោជកត្រូវរៀបចំការបញ្ចូលវត្ថុធាតុដើម ខ្សែសង្វាក់ផលិតកម្ម ការបញ្ចេញផលិតផលសំរេចឱ្យមានរបៀបរៀបរយ ធានាបាននូវសណ្តាប់ធ្នាប់ល្អក្នុងរោងជាង។

- រោងជាងដែលមានប្រើប្រព័ន្ធចំហាយទឹកបន្តតាមទុយយោរ៉ុព័ទ្ធដោយសារធាតុអាមីញ៉ង់ ត្រូវខណ្ឌដាច់ពីគេហើយត្រូវចាត់អ្នកឃ្លាំមើលប្រព័ន្ធនេះជាប្រចាំ និងត្រូវចាត់វិធានការចាំបាច់ជាបន្ទាន់នៅពេលមានបញ្ហា។

**ប្រការ ៣.- ឃ្លាំងស្តុកសន្និធិ**

ឃ្លាំងស្តុកសន្និធិសម្រាប់រោងចក្រ សហគ្រាសនីមួយៗ ត្រូវខណ្ឌចែកជា២យ៉ាងតិច គឺ :

- ឃ្លាំងស្តុកសន្និធិសារធាតុគីមី ត្រូវរៀបចំដាច់ដោយឡែក។ ឃ្លាំងស្តុកសន្និធិសារធាតុគីមីនេះ ត្រូវមានប្រព័ន្ធបញ្ចេញបញ្ចូលខ្យល់ត្រឹមត្រូវ មិនត្រូវពន្លឺត្រង់នៃព្រះអាទិត្យ និងត្រូវមានប្រព័ន្ធការពារចាំបាច់ផ្សេងៗទៀត សម្រាប់ទប់ទល់នឹងការបង្កឱ្យមានការប្រែរូបភាព ការបែកធ្លាយ ហូរចេញ ឬការបង្កឱ្យផ្ទុះឆេះ ជាដើម។

- ជាលក្ខណៈបណ្តោះអាសន្ន សារធាតុគីមីនីមួយៗ ទោះបានមកពីប្រភពណាក៏ដោយ ត្រូវមានសរសេរឈ្មោះគីមីជាភាសាឡាតាំងបិទភ្ជាប់នឹងដប ឬកំប៉ុងសារធាតុគីមីនោះ។ ម៉្យាងទៀតនិយោជកត្រូវមានឯកសារអធិប្បាយពីសារធាតុគីមីនីមួយៗជាភាសាបារាំង ឬអង់គ្លេស សម្រាប់មន្ត្រីមានសមត្ថកិច្ចត្រួតពិនិត្យនៅពេលចាំបាច់គ្រប់ពេល។

- សម្រាប់ឃ្លាំងស្តុកសន្និធិសម្ភារៈផលិតកម្មផ្សេងដទៃទៀត ក៏ត្រូវរៀបចំយ៉ាងណាឱ្យមានប្រពន្ធ័បញ្ចេញបញ្ចូលខ្យល់ត្រឹមត្រូវដែរ និងធានាឱ្យប្រព័ន្ធបញ្ចេញបញ្ចូលខ្យល់នោះ ត្រូវបានជួសជុលជាបន្ទាន់បើមានខូច។

- ស្បែក កៅស៊ូ ឬក្រណាត់ត្រូវទទួលស្តុកទំនិញទាំងនេះមួយរយៈឱ្យបាត់ក្លិន ធូលី ឬកំដៅសិនចាំយកមកប្រើសម្រាប់ការងារផលិតកម្ម។

- សញ្ញាការសុខភាពសុវត្ថិភាព និងបទបញ្ជាឃ្លាំងត្រូវបានសរសេរ និងដាក់ឱ្យបានត្រឹមត្រូវតាមទីកន្លែងងាយអាន ងាយយល់ និងថែរក្សាឱ្យនៅស្អាតជានិច្ច។

**ប្រការ ៤.- ការប្រើប្រាស់សារធាតុគីមី**

សារធាតុគីមីទាំងឡាយ ដែលមានប្រើក្នុងឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ និងដេរស្បែកជើងគ្រប់

ប្រភេទ រួមមានៈ

- ក្នុងរោងចក្រកាត់ដេរសម្លៀកបំពាក់ មានប្រើសារធាតុគីមីសម្រាប់ការងារផលិតកម្មគ្រប់ប្រភេទ ដូចជា (Hydrocarbures halogénés, Hydrocarbures aliphatiques et acycliques, Alcools, Acétates, Glycols......)

- ក្នុងរោងចក្រដេរស្បែកជើងមានប្រើសារធាតុគីមី ដូចជាកាវបិតគ្រប់ប្រភេទ ឬថ្នាំសស្លឹកជាដើម (Sels de chrome, P.V.C, Isocyanates, Cétone, Acétate d'éthyle, Acrylate de méthyle.....) ។

ដើម្បីសុវត្ថិភាពសម្រាប់កម្មករនិយោជិតទូទៅ និងជាសាធារណៈផង និយោជកត្រូវៈ

- បណ្តុះបណ្តាលបុគ្គលិកប្រើប្រាស់សារធាតុគីមីឱ្យបានត្រឹមត្រូវជាមុន មុននឹងប្រើគេឱ្យធ្វើការ

- ធានាថាសារធាតុគីមីទាំងអស់ត្រូវបានប្រើតែក្នុងមណ្ឌលខណ្ឌដាច់ដោយឡែក មិនសាយភាយទៅកន្លែងដទៃ

- រៀបចំប្រព័ន្ធបឺតខ្យល់ចេញក្រៅដោយធ្វើយ៉ាងណាធានាឱ្យខ្យល់ដែលបញ្ចេញទៅនោះមិនប៉ះពាល់ ដល់បរិស្ថានសាធារណៈ

- ធានាថាអ្នកធ្វើការជាមួយសារធាតុគីមី មានសម្ភារៈការពារគ្រប់គ្រាន់ និងមានប្រសិទ្ធិភាព

- ត្រូវគ្រោងឱ្យហើយជាស្រេចនូវច្រករត់ចេញ ពិសេសសម្រាប់ប្រើនៅពេលមានអាសន្ន

- សញ្ញាការសុខភាព សុវត្ថិភាព និងបទបញ្ជាការងារ ត្រូវបានសរសេរជាអក្សរខ្មែរ និងដាក់ឱ្យបានត្រឹមត្រូវតាម ទីកន្លែង ងាយអាន ងាយយល់ និងថែរក្សាឱ្យនៅស្អាតជានិច្ច ។

## ប្រការ ៥.- ការអប់រំសុវត្ថិភាពការងារដល់កម្មករនិយោជិត

និយោជកនៃគ្រប់សហគ្រាស រោងចក្រ សិប្បកម្មកាត់ដេរសម្លៀកបំពាក់ និងដេរស្បែកជើង មានកាតព្វកិច្ចធ្វើការអប់រំជាចាំបាច់ ដល់កម្មករនិយោជិត និងតំណាងរបស់ពួកគេ អំពីអនាម័យ សន្តិសុខការងារ និងអំពីបញ្ហាសុខភាព ដែលមាន ទាក់ទងដល់កិច្ចការនៅតាមប៉ុស្តិ៍ការងារនីមួយៗ ។

* ការអប់រំនេះនិងពន្យល់ប្រាប់ទៅកម្មករនិយោជិតអំពីៈ

- ហានិភ័យដែលបង្កឡើងដោយកត្តារូបធាតុ ( កំដៅ សំឡេង ពន្លឺ កាំរស្មី រំញ័រ ។ល។)

- ហានិភ័យនៃសារធាតុគីមី ជីវសាស្ត្រ មេកានិក អគ្គិសនី អគ្គិភ័យ

- ហានិភ័យដែលអាចនឹងមានដោយសារការងារនៅពេលយប់ ជាដើម

- វិធានការការពារមានប្រសិទ្ធិភាព

- កាយវិការ អាកប្បកិរិយានៅពេលមានអាសន្ន នៅពេលជួយសង្គ្រោះគ្នា ។

* ការអប់រំនេះត្រូវចាប់ផ្តើមនៅពេល :

- ចូលធ្វើការដំបូង

- ប្តូរប៉ុស្តិ៍ការងារ